**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ៣០៣ ក.ប/ស.ជ.ណ

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៦*

# សេចក្តីជូនដំណឹង

## ស្តីពី

## ការកំណត់មណ្ឌលប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មីឆ្នាំ២០១៦

**យោង ៖** សេចក្តីជូនដំណឹងលេខ ២៤៦ ក.ប/ស.ជ.ណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការជ្រើសរើសមន្ត្រីរាជការ និងសិស្ស-និស្សិតឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០១៦។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់បេក្ខជនទាំងអស់ឱ្យបានជ្រាបថា មណ្ឌលប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មីឆ្នាំ២០១៦ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦ គឺនៅមណ្ឌល "**វិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក**" ស្ថិតនៅតាមបណ្តោយផ្លូវកម្ពុជាក្រោម សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

__សូមបញ្ជាក់បន្ថែមដល់ បេក្ខជនទាំងអស់ផងដែរថា__ ៖

- បញ្ជីឈ្មោះបេក្ខជន នឹងបិទផ្សាយនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១០:០០ នាទីព្រឹក នៅមណ្ឌលប្រឡង (**វិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក**) និងនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- បេក្ខជន ដែលមានឈ្មោះក្នុងបញ្ជីត្រូវមកដល់បន្ទប់ប្រឡងនៅ**ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦** យ៉ាងយូរត្រឹមម៉ោង៦:០០ព្រឹក ដោយយកមកជាមួយនូវសាលាកប័ត្រឯកត្តជន (ចុងសន្លឹកដែលមានបិទរូបថត) និងប៊ិចខៀវតែប៉ុណ្ណោះ។ ក្នុងករណីបេក្ខជន ដែលមកដល់មណ្ឌលប្រឡងយឺត ១៥នាទី ក្រោយពីចែកវិញ្ញាសាប្រឡង គឺមិនត្រូវបានអនុញ្ញាតឱ្យចូលប្រឡងឡើយ។
- បេក្ខជន**មិនត្រូវយក ទូរស័ព្ទដៃ សម្ភារបរិក្ខារអេឡិចត្រូនិច និងឯកសារផ្សេងៗ** ចូលក្នុងមណ្ឌលប្រឡងឡើយ។ ក្នុងករណីរកឃើញថា បេក្ខជនរូបណាប្រព្រឹត្តខុសនិងបម្រាមនេះ គណៈកម្មការរៀបចំការប្រឡងនឹងបញ្ឈប់ការប្រឡងបេក្ខជនរូបនោះ និងដាក់ពិន្ទុកសូន្យ។

អាស្រ័យហេតុនេះ សូម បេក្ខជនទាំងអស់ មេត្តាជ្រាប និងអនុវត្តតាមការគួរ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩